ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

សន្និបាត (២០២៥)

# ឯកសារទស្សនាទាន
# ស្ដីពី
# ការអភិវឌ្ឍមូលធនយុវជនតាមរយៈសកម្មភាពអាទិភាព នៃអគ្គនាយកដ្ឋានយុវជន

## ១. សេចក្ដីផ្ដើម

កម្ពុជាបានចាត់ទុកយុវជនជាធនធានគន្លឹះសម្រាប់ការអភិវឌ្ឍសង្គមជាតិលើគ្រប់វិស័យ និងការថែរក្សាសន្តិភាពទាំងពេលបច្ចុប្បន្ន និងអនាគត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយសំខាន់ៗ សំដៅលើកកម្ពស់ និងអភិវឌ្ឍសមត្ថភាពយុវជនកម្ពុជា៖ (ក) យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផ្តោតលើអាទិភាព ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**, (ខ) គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា, (គ) ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣០ ដែលសំដៅធ្វើបរិវត្តកម្មឌីជីថលដោយចាប់យកឱកាស និងទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាក្នុងការអភិវឌ្ឍសង្គម (ឃ) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ដែលត្រូវបានរៀបចំឡើងឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ (ង) ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ។ល។

នៅក្នុងកិច្ចប្រជុំដំបូងគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវអនុសាសន៍ ដូចខាងក្រោម៖

ការលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពសាលារដ្ឋ ចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា តាមរយៈការពង្រឹងកិច្ចការសំខាន់ៗ រួមមាន៖

ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន

ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

ទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

ក្នុងការសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនូវការសម្រួចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាសម្រាប់ ឆ្នាំ២០២៣-២០២៨ ដោយបានកំណត់អាទិភាពបន្ថែម៖

ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន៖ រួមមាន កំណែទម្រង់នៅថ្នាក់ជាតិ កំណែទម្រង់នៅកម្រិតសាលារៀន ជាពិសេសគឺការបង្កើតស្តង់ដាសាលារៀនគំរូ។

ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស៖ រួមមាន ការអប់រំចរិយាធម៌ និងការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១។

ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

ទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

ទី៥. ការអប់រំឌីជីថល

ទី៦. ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

ទី៧. ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

ទី៨. ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

## ២. និយមន័យ

មូលធនយុវជន មានន័យថា យុវជនដែលមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា។

## ៣. សកម្មភាពអាទិភាពរបស់អនុវិស័យការអភិវឌ្ឍយុវជន

យុវជនប្រៀបបាននឹងរលកក្រោយ ដែលត្រូវបន្តវេនពីរលកមុន ត្រូវការជំនួយជ្រោមជ្រែងពីគ្រប់សមាសភាពពាក់ព័ន្ធ ដើម្បីធ្វើយ៉ាងណាស្នូចស្នួយយុវជនជំនាន់ក្រោយឱ្យប្រកបដោយសក្តានុពល ជាមូលធនយុវជន ជាជំហរនិងមានភាពធន់ដ៏រឹងមាំសម្រាប់ជ្រោងសសរជាតិទាំងមូល។

តាមរយៈចក្ខុវិស័យ និងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល អនុវិស័យការអភិវឌ្ឍយុវជនបានដាក់ចេញនូវអាទិភាពចំនួន០២ ដូចខាងក្រោម៖

១. រួមចំណែកអភិវឌ្ឍយុវជនឱ្យមានសក្តានុពលនៅក្នុងការអប់រំ ការងារ សុខភាព ការទទួលខុសត្រូវខ្ពស់ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍបុគ្គល គ្រួសារ សង្គម ប្រទេសជាតិ និងសាកលលោក។

២. បណ្តុះបំណិនសតវត្សរ៍ទី២១ ដល់យុវជន និងពង្រឹងសមត្ថភាពយុវជនឱ្យមានវិជ្ជាសម្បទា បំណិន សម្បទា ចរិយាសម្បទា និងកាយសម្បទា។




ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា កងឈ្លបកាយរឹទ្ធិ ក្លឹបសកម្មភាព/ក្លឹបអប់រំមិត្ត កម្មវិធីអភិវឌ្ឍសមត្ថភាព សុទ្ធសឹងជាយន្តការគន្លឹះក្នុងការសម្រេចបានសកម្មភាពអាទិភាពរបស់អនុវិស័យ និងគាំទ្រដល់ការសម្រួចអាទិភាពវិស័យអប់រំ យុវជន និងកីឡា ក៏ដូចជាការអនុវត្តស្តង់ដាសាលារៀនគំរូ សំដៅដល់ការ គាំទ្រការរៀន និងការបង្រៀននៅតាមសាលារៀន ជាពិសេសការអប់រំយុវជន និងកុមារឱ្យមានគុណធម៌ សីលធម៌ និងឥរិយាបថល្អប្រសើរ ក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ និងជាពលរដ្ឋល្អក្នុងសង្គមជាតិ។

ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា បានជួយបណ្តុះបំណិនសតវត្សរ៍ទី២១ ដែលសំដៅលើចំណេះដឹង បំណិនជីវិត បំណិនវិជ្ជាជីវៈ បំណិនឌីជីថល បំណិនត្រិះរិះពិចារណា ការធ្វើការងារជាក្រុម ទម្លាប់ និងឥរិយាបថ ដែលមានភាពចាំបាច់សម្រាប់ភាពជោគជ័យរបស់យុវជននៅក្នុងសង្គមបច្ចុប្បន្ន ជាពិសេស គឺការត្រៀមខ្លួនសម្រាប់ការបន្តការ

សិក្សានៅថ្នាក់ឧត្តមសិក្សា ការចូលបំពេញការងារ និងការឈានជើងចូលជីវិតជាមនុស្សពេញវ័យ អាចចូលរួមអភិវឌ្ឍ និងរក្សាសុខដុមនីយកម្មប្រទេសជាតិ។

ជាងនេះទៅទៀត ការអភិវឌ្ឍសមត្ថភាពយុវជន ត្រូវបានធ្វើឡើងតាមរយៈកម្មវិធីសំខាន់ៗ រួមមាន៖

- កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ-ខេត្ត
- កម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១
- កម្មវិធីយុវជន២១
- កម្មវិធីចលនាប្រឡងប្រណាំង ៣ល្អ កូនល្អ សិស្សល្អ មិត្តល្អ
- កម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ
- កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន តាមអ៊ីនធឺណេត
- កម្មវិធីប្រកួតប្រជែងផែនការអាជីវកម្ម
- កម្មវិធីអគ្គរកម្មឌីជីថល
- កម្មវិធីជំនាញទន់សម្រាប់យុវជន
- កម្មវិធីប្រកួតភ្លេងកាយរឹទ្ធិថ្នាក់ជាតិ
- កម្មវិធីកាយរឹទ្ធិថ្មើរព្រៃ និងការងារសហគមន៍
- កម្មវិធីបោះជំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិ
- កម្មវិធីប្រកួតរូបថតកាយរឹទ្ធិថ្នាក់ជាតិ
- JOTA-JOTI
- កម្មវិធីមនសិការពលរដ្ឋល្អ
- កម្មវិធីបោះជំរំយុវជនជាសាកល
- កម្មវិធីផ្លាស់ប្តូរយុវជនអន្តរជាតិ ។ល។

## ៤. ផលជះសម្រាប់យុវជន

កម្មវិធីអភិវឌ្ឍសមត្ថភាពយុវជនដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចសមត្ថភាព និងតម្រង់ផ្លូវដល់យុវជនកម្ពុជា។ តាមរយៈការចូលរួមជាប្រតិភូ និងជាយុវជនស្ម័គ្រចិត្តរបស់អនុវិស័យការអភិវឌ្ឍយុវជន យុវជនកម្ពុជាទទួលបានការអភិវឌ្ឍចំណេះដឹងនិងសមត្ថភាព ទំនុកចិត្តលើខ្លួនឯង បំណិនជីវិត បំណិនការងារជាក្រុម បំណិនដោះស្រាយបញ្ហា ស្មារតីទទួលខុសត្រូវ ស្មារតីចូលរួមចំណែក ភាពជាអ្នកដឹកនាំ ដែលជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់យុវជនឈានជើងចូលទៅក្នុងជីវិតរស់នៅក្នុងសង្គមជាក់ស្តែង និងក្លាយជាពលរដ្ឋល្អក្នុងសង្គម។

ការអប់រំជំនាញ និងការអភិវឌ្ឍសមត្ថភាពយុវជន គឺជាអាទិភាពរបស់អនុវិស័យការអភិវឌ្ឍយុវជន។ អនុវិស័យបានបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ បច្ចេកវិទ្យា ស្នែម និងចំណេះដឹងទូទៅជាមូលដ្ឋានដល់យុវជនទាំងក្នុង និងក្រៅប្រព័ន្ធសិក្សា ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តសកម្មភាពគម្រោងជាក់ស្តែង។ ការអប់រំ បច្ចេកវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេស និងវិជ្ជាជីវៈនៃកម្មវិធីអភិវឌ្ឍយុវជនស្របតាមបរិបទសតវត្សរ៍ទី២១ ផ្តល់ឱកាសដល់យុវជនបានបំពេញបន្ថែមលើចំណេះដឹងពីក្នុងថ្នាក់រៀន និងសម្រេចជំនាញ និងសមត្ថភាពរបស់ខ្លួនតាមរយៈការអនុវត្តជាក់ស្តែង សំដៅបង្កើនផលិតភាព និងភាពធន់ និងជាទុនដល់យុវជនអាចយកទៅប្រកបមុខរបរដោយខ្លួនឯងបាន ឬបំពេញការងារទៅតាមជំនាញរបស់ខ្លួន និងមានលទ្ធភាពរកប្រាក់ចំណូលជួយដល់ជីវភាពខ្លួនឯង ក្រុមគ្រួសារ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្រតិភូយុវជន និងយុវជនស្ម័គ្រចិត្ត ទទួលបានជំនាញ បទពិសោធ និងកសាងបណ្តាញដែលមានអត្ថប្រយោជន៍ចំពោះអាជីពការងាររបស់ពួកគេនាពេលអនាគត។ ក្រៅពីនោះ សហគមន៍នានាបានទទួលស្គាល់គំនិតផ្តួចផ្តើមនានា ដែលដឹកនាំដោយយុវជន ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន និងសហគមន៍។

## ៥. បញ្ហាប្រឈម

- កម្មវិធីយុវជននៅមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់យុវជននៅតាមរាជធានី ខេត្ត
- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារ ការផ្តល់សេវាកម្ម និងការអនុវត្តកម្មវិធីយុវជននៅតាមមជ្ឈមណ្ឌលយុវជន មិនទាន់ឆ្លើយតបទៅនឹងការបណ្តុះបណ្តាលសតវត្សរ៍ទី២១
- ធនធានមនុស្សដែលមានវិជ្ជាជីវៈការអភិវឌ្ឍយុវជននៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការកម្មវិធីយុវជន។

## ៦. ដំណោះស្រាយ និងទិសដៅបន្ត

- ធ្វើទំនើបកម្ម និងពង្រីកកម្មវិធីយុវជនឱ្យឆ្លើយតបនឹងតម្រូវការរបស់យុវជននៅតាមរាជធានី ខេត្ត
- វិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារ ការផ្តល់សេវាកម្ម និងការអនុវត្តកម្មវិធីយុវជននៅតាមមជ្ឈមណ្ឌលយុវជន ឱ្យឆ្លើយតបទៅនឹងការបណ្តុះបណ្តាលសតវត្សរ៍ទី២១
- អភិវឌ្ឍធនធានមនុស្សដែលមានវិជ្ជាជីវៈការអភិវឌ្ឍយុវជន ឱ្យឆ្លើយតបទៅនឹងតម្រូវការកម្មវិធីយុវជន
- បង្កើនកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

## ៧. សេចក្តីសន្និដ្ឋាន

អនុវិស័យការអភិវឌ្ឍយុវជន ពិតមានសារៈសំខាន់ក្នុងការជំរុញ និងអប់រំឥរិយាបថ សីលធម៌ និងគុណធម៌របស់សិស្សឱ្យក្លាយខ្លួនជាកូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ និងជាមូលធនយុវជនសម្រាប់សង្គមជាតិកម្ពុជា។ រាល់សកម្មភាពរបស់អនុវិស័យបានឆ្លើយតបយ៉ាងវិជ្ជមានទៅនឹងគោលនយោបាយសំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអាទិភាពទី២ នៃអនុសាសន៍របស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងការសម្រួចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាសម្រាប់ ឆ្នាំ២០២៣-២០២៨ ផ្តោតលើសកម្មភាពក្រៅម៉ោងសិក្សារបស់ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស។

Kingdom of Cambodia
Nation Religion King

Ministry of Education, Youth and Sport
Congress (2025)

# CONCEPT PAPER
# ON
# Development of Youth Capital Through the Priority Activities Implementation of the General Department of Youth

## 1. Introduction

Cambodia considers youth as a key resource for national social development across all sectors and for maintaining peace, both now and in the future. In this regard, the Royal Government of Cambodia has formulated strategies and key policies aimed at enhancing and developing the capabilities of Cambodian youth, including: (A) Pentagonal Strategy Phase 1, focusing on five priorities: **People, Roads, Water, Electricity,** and **Technology.** (B) National Policy on Cambodian Youth Development. (C) Cambodia's Digital Economic and Social Policy Framework (2021–2030), which aims to leverage digital transformation to maximize opportunities and benefits from technological advancements. (D) Education Strategic Plan (2024-2028), aligned with the government's Phase 1 Pentagonal Strategy and Cambodia's long-term vision for 2030 and 2050. (E) National Action Plan for Cambodian Youth Development, among others.

During the first cabinet meeting of the 7th mandate on August 24, 2023, **Samdech Moha Borvor Thipadei Hun Manet, Prime Minister of the Kingdom of Cambodia,** emphasized the following recommendations:

Improving education quality by strengthening public schools from kindergarten to secondary levels through key initiatives:

1. Strengthening school governance.
2. Revising curricula and extracurricular activities to align with needs for knowledge, discipline, ethics, and student behavior.
3. Prioritizing student health through child nutrition programs and food quality control in schools.
4. Encouraging parental, guardian, and community participation in education under the slogan "Partnership Between Public and Community for Education."

To achieve these goals, the Ministry of Education, Youth, and Sport has prioritized reforms (2023-2028), including:

1. Strengthening school governance through national and school-level reforms, especially establishing model school standards.
2. Revising curricula and extracurricular activities to enhance 21st-century skills, ethics, and behavior.
3. Student health programs and school meal quality control.
4. Promoting parental and community engagement in education.
5. Digital education.
6. Establishing excellence centers in higher education institutions.
7. Building systems and capacity development.
8. Promoting physical education and sport.

## 2. Definition

Youth Capital refers to youth who possess intellectual, skill-based, ethical, and physical competencies.

## 3. Priority Activities of the Youth Development Sub-Sector

Youth are the "next wave" that must inherit the legacy of previous generations. They require support from all stakeholders to empower them to become resilient youth capital and pillars for national development.

The sub-sector has outlined two priorities aligned with the government's vision and policies:

1. Empowering youth in education, employment, health, responsibility, decision-making, and contributions to personal, family, societal, national, and global development.
2. Developing 21st-century skills to enhance youth competencies in knowledge, skills, ethics, and physical well-being.



Cambodian Youth Council, Cambodian Children's Council, Scout Patrol, Activity/Education Clubs, and Capacity Development Programs are key mechanisms for achieving the priorities of the sub-sector and supporting the advancement of education, youth, and sports. They also implement model school standards aimed at supporting learning and teaching in schools, particularly focusing on youth and children's education to instill good morals, ethics, and behavior. This helps them become good children, good students, good friends, and good citizens in society.

The Cambodian Youth Council and Cambodian Children's Council have contributed to developing 21st-century skills, which include knowledge, life skills, vocational skills, digital skills, critical thinking, teamwork, habits, and behaviors necessary for the success of youth in modern society. Specifically, they prepare youth for higher education, employment, and transitioning into adulthood, enabling them to participate in and maintain the sustainable development of the nation.

Programs to develop youth capabilities include:

- National-provincial youth debates.
- 21st-century youth innovation competitions.
- Youth 21 Program.
- "3 Goods" movement: Good Child, Good Student, Good Friend.
- Community volunteer programs.
- Digital literacy initiatives.
- Entrepreneurship competitions.
- Digital literacy program
- Soft skills training.
- National Scout Music Competition
- Wilderness Scouting and Community Service Program
- National Senior Scout Camp Program
- National Scout Photo Competition
- JOTA-JOTI
- Good Citizenship Program
- Global Youth Camp Program
- International Youth Exchange Program, etc.

## 4. Impact on Youth

Youth development programs play a crucial role in enhancing the capabilities and guiding Cambodian youth. Through participation as delegates and volunteers under the Department of Youth Development, Cambodian youth gain knowledge, self-confidence, life skills, teamwork abilities, problem-solving skills, a sense of responsibility, a spirit of contribution, and leadership qualities. These form a vital foundation for young people to transition into real-life societal contexts and become good citizens.

Skill education and youth capacity development are priorities of the Department of Youth Development. The department provides technical, vocational, technological, STEM (Science, Technology, Engineering, Mathematics), and general foundational training to youth both within and outside the formal education system. This bridges theory with practical project implementation. The youth development programs align with 21st-century contexts, offering opportunities for youth to supplement classroom knowledge, refine their skills and abilities through hands-on practice, and enhance productivity and resilience. These programs equip youth with capital to pursue self-employment, work in their fields of expertise, earn income to support their livelihoods and families, and contribute to economic and social development. Youth delegates and volunteers gain skills, experience, and networks that benefit their future careers. Beyond this, communities have recognized various youth-led initiatives that contribute to school and community development.

## 5. Challenges

- Youth programs in provinces still fail to meet local needs.
- Insufficient investment in infrastructure, resources, and service delivery for 21st-century skill development.
- Shortage of specialized human resources for youth program implementation.

## 6. Solutions and Future Directions

- Modernize and expand youth programs to meet local demands.
- Increase investment in infrastructure, resources, and youth center services.
- Develop specialized human resources for youth programs.
- Strengthen partnerships with ministries, institutions, and stakeholders.

## 7. Conclusion

The Youth Development Sub-Sector is vital in nurturing youth to become ethical, moral, and competent citizens as youth capital for Cambodian society. Its activities align with the government's policies, particularly Priority 2 of the Prime Minister's recommendations and the education reform agenda (2023–2028). By focusing on extracurricular activities, the sub-sector strengthens students' knowledge, discipline, ethics, and behavior, ensuring youth contribute meaningfully to national development.